ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តកំពង់ឆ្នាំង

លេខ: ១២០ សសរ

កំពង់ឆ្នាំង, ថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ ២០១១

# សេចក្តីសម្រេច
## ស្តីពី
## ការធ្វើប្រតិភូកម្មលើការងារនីត្យានុកូលកម្ម លើឯកសារថតចម្លងផ្សេងៗ និងការងារសាងសង់

## អភិបាលខេត្តកំពង់ឆ្នាំង

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៥៦ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាល ខេត្តកំពង់ឆ្នាំង
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០៩ /៥៩១ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីការទទួលស្គាល់ សមាសភាពក្រុមប្រឹក្សា ខេត្តកំពង់ឆ្នាំងក្នុងអាណត្តិទី១
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងលិខិតលេខ ៦៩៣ សជណ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១ របស់ក្រសួងមហាផ្ទៃស្តីពីការធ្វើប្រតិភូកម្មលើការងារនីត្យានុកូលកម្មលើឯកសារថតចម្លងផ្សេងៗឱ្យទៅក្រុងគោលដៅដែលមានការិយាល័យច្រកចេញចូលតែមួយ
- យោងលិខិតលេខ ៦៩៤ សជណ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១ របស់ក្រសួងមហាផ្ទៃស្តីពីការធ្វើប្រតិភូកម្មមុខងារភារកិច្ចដល់ក្រុងបាត់ដំបង បាវិត កំពង់ឆ្នាំង ពោធិសាត់ ច្បារមន កំពត ដូនកែវ និងក្រុងខេមរភូមិន្ទអំពីការងារសាងសង់ ។

## ស ម្រេ ច

**ប្រការ ១ .-**

ត្រូវបានធ្វើប្រតិភូកម្មឱ្យទៅអភិបាលក្រុងកំពង់ឆ្នាំង ដែលមានការិយាល័យច្រកចេញចូលតែមួយលើការងារដូចខាងក្រោម ÷

**១.១ ការងារនីត្យានុកូលកម្មលើឯកសារថតចម្លងផ្សេងៗ:**

១ - វិញ្ញាបនបត្របញ្ជាក់ការសិក្សា

២ - វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាកម្រិត១

៣ - វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាកម្រិត២

៤ - វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ

៥ - វិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ

៦ - វិញ្ញាបនបត្របញ្ចប់ការសិក្សាថ្នាក់ទី ១២

៧ - វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម

៨ - វិញ្ញាបនបត្របញ្ជាក់ប្រកបរបរអាជីវកម្ម

៩ - វិញ្ញាបនបត្របណ្ដោះអាសន្នថ្នាក់បរិញ្ញាបត្រ

១០ - វិញ្ញាបនបត្រ

១១ - លិខិតបញ្ជាក់លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាកម្រិត១

១២ - សញ្ញាបត្រមធ្យមសិក្សាកម្រិត២ ( បំពេញវិជ្ជា )

១៣ - សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

១៤ - សញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ

១៥ - សញ្ញាបត្រមធ្យមសិក្សា

១៦ - សញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម

១៧ - ព្រឹត្តិបត្រលទ្ធផលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

១៨ - បរិញ្ញាបត្រ

១៩ - បរិញ្ញាបត្ររង

២០ - លិខិតបញ្ជាក់ការសិក្សា

២១ - អត្តសញ្ញាណប័ណ្ណ

២២ - សៀវភៅស្នាក់នៅ

២៣ - ប័ណ្ណសម្គាល់យានយន្ត

២៤ - ព្រឹត្តិបត្រពិន្ទុ

២៥ - ពាក្យសុំបញ្ជាក់ សញ្ញាបត្រមធ្យមសិក្សាកម្រិត២ចំពោះទូទៅ

**១.២ អំពីការសាងសង់:**

ផ្តល់សេវាសាធារណៈលើការងារសាងសង់លំនៅដ្ឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់មិនលើសពី ៥០០ ម៉ែត្រក្រឡា និង មានកម្ពស់មិនលើស ២ ជាន់ គិតទាំងជាន់ផ្ទាល់ដី និងរបងដែលមានកម្ពស់មិនលើស ២ ម៉ែត្រ គិតលើកម្រិតកម្ពស់ដីនៅជើងរបង ។

**ប្រការ ២ ..**

អភិបាលក្រុងកំពង់ឆ្នាំងមានមុខងារអនុវត្តន៍តាមខ្លឹមសារ:

១ - អនុក្រឹត្យលេខ ៨៦ អនក្រ.ក្រ ចុះថ្ងៃទី ១៩ ខែ ធ្នូឆ្នាំ ១៩៩៧ ស្តីពីការអនុញ្ញាតសាងសង់

២ - សេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី ៣០ ខែមិថុនាឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតការិយាល័យ ច្រកចេញ ចូលតែមួយនិងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក

៣ - ប្រកាសលេខ ៩២៨ ប្រ.ក ចុះថ្ងៃទី ១២ ខែមីនាឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យ ច្រកចេញ ចូលតែមួយនៅថ្នាក់ក្រុង ស្រុក ខណ្ឌគោលដៅ

៤ - សេចក្តីណែនាំលេខ ០០២ សណន/អសណ ចុះថ្ងៃទី ១៥ ខែមីនាឆ្នាំ ២០១១ ស្តីពីការផ្តល់សេវាសាធារណៈ ផ្នែកសំណង់នៅក្រុងបានលុង ខេត្តរតនគិរី ក្រុងបាវិត ខេត្តស្វាយរៀង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ក្រុងកំពត ខេត្តកំពត ក្រុងខេមរភូមិន្ទ ខេត្តកោះកុង និងក្រុងដូនកែវ ខេត្តតាកែវ

៥ - លិខិតលេខ ១៧៩ ដនស/អសណ ចុះថ្ងៃទី ១៥ ខែមីនាឆ្នាំ ២០១១ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ។

**ប្រការ ៣ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ .-**

នាយក នាយករងរដ្ឋបាលសាលាខេត្ត និងអភិបាលក្រុងកំពង់ឆ្នាំង ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

**អភិបាលខេត្ត**

**ឈូច_ហ៊ីរ**

**ចម្លងជូន**

- *ក្រសួងមហាផ្ទៃ*
- *ក្រសួង រៀបចំដែនដីនគរូបនីយកម្មនិងសំណង់*
  *( សូមជូនជ្រាប )*
- *សាលាក្រុង សាលាស្រុក*
- *មន្ទីរ អង្គភាពជុំវិញខេត្ត*
- *ដូចប្រការ ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាក្រុងកំពង់ឆ្នាំង

ការិយាល័យច្រកចេញចូលតែមួយ

លេខ: ១១ សរណ

សាលាខេត្តកំពង់ឆ្នាំង

ចូល

លេខ: 426

ថ្ងៃទី 28 ខែ 07 ឆ្នាំ 2011 ម៉ោង.......

បញ្ញើ:

**គោរពជូន**

**ឯកឧត្តមអភិបាលខេត្តកំពង់ឆ្នាំង**

កម្មវត្ថុ: សំណើសុំការកំណត់តំលៃសេវានីត្យានុកូលកម្ម ។

យោង: -សេចក្តីសំរេចលេខ ១២០ ស.ស.រ របស់ឯកឧត្តមអភិបាលខេត្តកំពង់ឆ្នាំង ។

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរពជូនឯកឧត្តមមេត្តាជ្រាបថា ដើម្បីអោយការងារនីត្យានុកូលកម្មមានតម្លាភាពប្រកបទៅដោយសមធម៌ សមស្របទៅនឹងសភាពជាក់ស្តែង នៃក្រុងគោលដៅដែលទទួលបានការធ្វើប្រតិភូកម្មមុខងារនិងភារកិច្ច សាលាក្រុងកំពង់ឆ្នាំងបានព្រាងកំណត់នូវតារាងតំលៃដូចមានភ្ជាប់ជូនខាងក្រោម ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូមឯកឧត្តមមេត្តាពិនិត្យសំរេចដោយក្តីអនុគ្រោះ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅកំពង់ឆ្នាំង,ថ្ងៃទី២៥ខែកក្កដាឆ្នាំ ២០១១

អភិបាលក្រុងកំពង់ឆ្នាំង

ហែ_មនោរម្យ

ឈុច_ភឿន

# តារាងតម្លៃសេវានីត្យានុកូលកម្ម

| ល.រ | ប្រភេទលិខិត | តម្លៃសេវាកម្មក្នុងមួយសន្លឹក( គិតជាប្រាក់រៀល ) | | |
|---|---|---|---|---|
| | | សេវាប្រតិបត្តិ | តែមប្រើ | ទឹកប្រាក់សរុប |
| ១ | វិញ្ញាបនបត្របញ្ជាក់ការសិក្សា | 500 | 300 | 800 |
| ២ | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាកំរិត១ | 500 | 300 | 800 |
| ៣ | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាកំរិត២ | 500 | 300 | 800 |
| ៤ | វិញ្ញាបនបត្របណ្ដោះរាសន្ន មធ្យមសិក្សាបឋមភូមិ | 500 | 300 | 800 |
| ៥ | វិញ្ញាបនបត្របណ្ដោះអាសន្ន មធ្យមសិក្សាទុតិយភូមិ | 500 | 300 | 800 |
| ៦ | វិញ្ញាបនបត្របញ្ជាក់ការសិក្សា ថ្នាក់ទី១២ | 500 | 300 | 800 |
| ៧ | វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម | 700 | 300 | 1,000 |
| ៨ | វិញ្ញាបនបត្រប្រកបអាជីវកម្ម | 700 | 300 | 1,000 |
| ៩ | វិញ្ញាបនបត្របវិញ្ញាបត្របណ្ដោះអាសន្ន | 700 | 300 | 1,000 |
| ១០ | លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកំរិត១ | 500 | 300 | 800 |
| ១១ | សញ្ញាបត្រមធ្យមសិក្សាកំរិត២(បំពេញវិជ្ជា) | 500 | 300 | 800 |
| ១២ | សញ្ញាបត្រមធ្យមសិក្សា ទុតិយភូមិ | 500 | 300 | 800 |
| ១៣ | សញ្ញាបត្រមធ្យមសិក្សា គរុកោសល្យ | 500 | 300 | 800 |
| ១៤ | សញ្ញាបត្រមធ្យមសិក្សា | 500 | 300 | 800 |
| ១៥ | សញ្ញាបត្រគ្រូបង្រៀនកំរិតឧត្ដម | 700 | 300 | 1,000 |
| ១៦ | ព្រឹត្តិបត្រលទ្ធផល ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | 700 | 300 | 1,000 |
| ១៨ | សញ្ញាបត្របរិញ្ញាបត្រ | 700 | 300 | 1,000 |
| ១៩ | សញ្ញាបត្របរិញ្ញាបត្ររង | 700 | 300 | 1,000 |
| ២០ | លិខិតបញ្ជាក់ការសិក្សាផ្សេងៗទៀត | 700 | 300 | 1,000 |
| ២១ | អត្តសញ្ញាណប័ណ្ណ | 700 | 300 | 1,000 |
| ២២ | សៀវភៅស្នាក់នៅ | 700 | 300 | 1,000 |
| ២៣ | ប័ណ្ណសំគាល់យានយន្ត | 700 | 300 | 1,000 |
| ២៤ | ព្រឹត្តិបត្រពិន្ទុ | 700 | 300 | 1,000 |
| ២៥ | ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកំរិត២ចំណោះដឹងទូទៅ | 500 | 300 | 800 |

16/08/